ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ថ្ងៃពុធ ១៦កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

លេខ: ៣៣៣៣ វ.ស.ក

រាជធានីភ្នំពេញ ថ្ងៃទី..០៥.....ខែ..សីហា..ឆ្នាំ ២០២០

## សូមគោរពជូន
## ឯកឧត្តម ឈិត សុខុន រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

**កម្មវត្ថុ៖** សំណើសុំចេញសេចក្តីប្រកាសបញ្ឈប់ការរំលាយបំណែក ឬបុរាណវត្ថុពេញលេញអំពីលោហធាតុ ដើម្បីសិតព្រះពុទ្ធបដិមា ឬរូបចម្លាក់ផ្សេងៗនៅតាមវត្តអារាម។

**យោង** ៖ សារាចរអន្តរក្រសួងចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការហាមឃាត់ដាច់ខាតរាល់សកម្មភាពវាយកម្ទេចបំផ្លិចបំផ្លាញ ធ្វើឲ្យបាត់បង់ ឬធ្វើឲ្យខូចខាត និងការប្តូររូបរាងនូវសំណង់បុរាណ គំនូរបុរាណ និងវត្ថុបុរាណនៅតាមវត្តអារាមក្នុងព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** ជ្រាបថា៖ នារយៈកាលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាយើងដែលមានក្រសួងជំនាញក្រោមឱវាទជាសេនាធិការ បានខិតខំខ្នះខ្នែង ក្នុងការការពារបុរាណវត្ថុ ប្រាសាទ សំណង់ប្រវត្តិសាស្ត្រ ស្ថានីយ៍បុរាណនានា ដើម្បីជាប្រយោជន៍សម្រាប់កូនចៅជំនាន់ក្រោយបានស្គាល់ និងបានសិក្សារៀនសូត្រអំពីស្នាដៃបុព្វបុរសខ្មែរយើង។ ការខិតខំប្រឹងប្រែងរបស់ក្រសួងជំនាញបានផ្តល់លទ្ធផលជាវិជ្ជមានគួរជាទីកត់សម្គាល់ ជាពិសេសគឺការចូលរួមទប់ស្កាត់ការបំផ្លិចបំផ្លាញបុរាណដ្ឋាន និងការជួញដូរវត្ថុបុរាណទៅក្រៅប្រទេស។ ទន្ទឹមនឹងការខិតខំប្រឹងប្រែងថែរក្សាការពារនេះ ក្រសួងសង្កេតឃើញថាហានិភ័យនៃការបំផ្លាញបុរាណវត្ថុខ្មែរដែលគួរឲ្យព្រួយបារម្ភ ខ្លាំងនាពេលបច្ចុប្បន្ននេះ គឺនិន្នាការនៃការបន្តប្រពៃណីសិតព្រះពុទ្ធបដិមា ឬចម្លាក់ផ្សេងៗដោយប្រើប្រាស់បំណែក ឬបុរាណវត្ថុពេញលេញអំពីលោហធាតុរួមមាន សំរឹទ្ធ ប្រាក់ និងមាស លាយជាមួយស្ពាន់ ឬទង់ដែងថ្មី នៅបន្តធ្វើតាមវត្តអារាមដោយឥតស្រាកស្រាន្ត។ ជាក់ស្តែងកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ក្រសួងទើបទទួលបានរបាយការណ៍ពីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តព្រៃវែង ស្តីពីសកម្មភាពនៃការត្រៀមយកវត្ថុបុរាណមួយចំនួនសម្រាប់ ទៅរំលាយសិតព្រះនៅវត្តពារាំង ស្ថិតនៅភូមិពារាំង ឃុំរាប ស្រុកពារាំង។

ខ្ញុំដឹងថាសកម្មភាពខាងលើនេះជាជំនឿដែលបន្តពីបុរាណកាលមក ប៉ុន្តែជំនឿបែបនេះមិនគួរបន្តទៀតឡើយ ត្បិតនាពេលបច្ចុប្បន្នប្រទេសយើងកំពុងអនុវត្តច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ និងអនុក្រឹត្យ ស្តីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដែលខ្លឹមសារនៃច្បាប់គឺការពារមិនឲ្យជនណាម្នាក់បំផ្លាញបេតិកភណ្ឌវប្បធម៌ជាតិ និងសម្បត្តិវប្បធម៌ទូទៅឡើយ។ ក្រៅពីយន្តការច្បាប់រដ្ឋខាងលើ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងធម្មការនិងសាសនា ក៏បានចេញសារាចរអន្តរក្រសួងមួយណែនាំកាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការហាមឃាត់

ទូរសព្ទ / ទូរសារ: 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ដាច់ខាតរាល់សកម្មភាពវាយកម្ទេចបំផ្លិចបំផ្លាញ ធ្វើឲ្យបាត់បង់ ឬធ្វើឲ្យខូចខាតនិងការប្ដូររូបរាងនូវសំណង់បុរាណ គំនូរបុរាណ និងវត្ថុបុរាណនៅតាមវត្តអារាមក្នុងព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** ពិនិត្យ និងសម្រេចតាមការគួរ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

**ចម្លងជូន៖**

-ក្រសួងមហាផ្ទៃ

-ខុទ្ទកាល័យលោកជំទាវរដ្ឋមន្ត្រី

-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

-អគ្គនាយកដ្ឋានបេតិកភណ្ឌ

-រដ្ឋបាលរាជធានី-ខេត្ត

-មន្ទីរធម្មការនិងសាសនារាជធានី-ខេត្ត

"ដើម្បីជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ